ទម្រង់ទី២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**

លេខ៦៣៨សជណ

កណ្តាល, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦

## សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

រដ្ឋបាលខេត្តកណ្តាល នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់ សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទង នឹង ប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យ ដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុង ពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការ បុរេលក្ខណសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរក ឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពីពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការនិងវិនិយោគនៃសាលាខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី០៣ ខែតុលាឆ្នាំ ២០១៦ វេលាម៉ោង ៥ ល្ងាច។ ចំពោះអ្នកទទួលការ ដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុង បញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគដោយឥតបង់ថ្លៃ តាមអាសយដ្ឋាន នៅទីចាត់ការផែនការ និង វិនិយោគដែលមានទីតាំងនៅ ក្នុងបរិវេណសាលាខេត្តកណ្តាល ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប។

**អភិបាលខេត្ត**

ម៉ៅ ភិរុណ